# វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ
## មុខវិជ្ជាស្រាវជ្រាវអប់រំ
## ឆ្នាំទី៣ ឆមាសទី១

# មេរៀនទី១៖ សញ្ញាណទូទៅនៃការស្រាវជ្រាវអប់រំ
## មេរៀនសង្ខេប

## I. និយមន័យនៃការស្រាវជ្រាវ

- ការស្រាវជ្រាវ (Research) គឺជាដំណើរការសិក្សា និងស្វែងរកយ៉ាងប្រព័ន្ធ ដោយប្រើវិធីសាស្ត្រវិទ្យាសាស្ត្រ ដើម្បីបង្កើតចំណេះដឹងថ្មី ឬដោះស្រាយបញ្ហាមួយ។ វារួមបញ្ចូលនឹងការប្រមូលទិន្នន័យ ការវិភាគ ការបកស្រាយ និងការបញ្ចេញសន្និដ្ឋាន។
- ការស្រាវជ្រាវគឺការបង្កើតចំណេះដឹងថ្មី ឬការប្រើប្រាស់ចំណេះដឹងមានស្រាប់ដោយភាពច្នៃប្រឌិត ដើម្បីបង្កើតគោលគំនិត វិធីសាស្ត្រ និងការយល់ដឹងថ្មីៗ (Western Sydney University, 2020)។
- ការស្រាវជ្រាវគឺការស្វែងរកជាប្រព័ន្ធនូវព័ត៌មានពាក់ព័ន្ធនឹងប្រធានបទ ឬបញ្ហាអ្វីមួយ (Aquino, p.1)

**ពាក្យសំខាន់ៗក្នុងនិយមន័យ៖**

- ស្វែងរកមានលក្ខណៈជាប្រព័ន្ធ (Systematic investigation)
- ប្រើវិធីសាស្ត្រវិទ្យាសាស្ត្រ (Scientific methods)
- ផ្តោតលើបញ្ហាឬសំណួរ (Focused problem/question)
- បង្កើតចំណេះដឹងថ្មី (Generate new knowledge)

## II.គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវគឺការបង្កើតចំណេះដឹងថ្មីឬពង្រឹងចំណេះដឹងដែលមានស្រាប់ ដើម្បីឆ្លើយតបទៅ នឹងបញ្ហា ឬសំណួរដែលមាន។ ជាទូទៅគោលបំណងនៃការស្រាវជ្រាវរួមមាន៖

- ស្វែងរក និងប្រមូលចំណេះដឹងថ្មីៗដើម្បីបន្ថែមចំណេះដឹងក្នុងវិស័យណាមួយ។
- ដោះស្រាយបញ្ហាជាក់លាក់ស្រាវជ្រាវជួយបង្ហាញដំណោះស្រាយសម្រាប់បញ្ហាដែលកើតមានក្នុងសង្គមអប់រំ សេដ្ឋកិច្ច ឬវិទ្យាសាស្ត្រ។
- បញ្ជាក់ និងផ្ទៀងផ្ទាត់ទ្រឹស្តីដើម្បីបញ្ជាក់ថាទ្រឹស្តី ឬគោលគំនិតណាមួយមានសុពលភាព និងអាច អនុវត្តបាន។
- ជួយក្នុងការសម្រេចចិត្តលទ្ធផលស្រាវជ្រាវអាចផ្តល់ជាផ្លូវណែនាំដល់អ្នកគ្រប់គ្រង គ្រូបង្រៀន ឬអ្នកសម្រេចចិត្តក្នុងគោលនយោបាយ។
- លើកកម្ពស់ការអភិវឌ្ឍសង្គមដោយការបង្កើតចំណេះដឹង និងដំណោះស្រាយថ្មីៗ ដែលអាចអនុវត្តបានក្នុងជីវិតពិត។

## III.ការស្រាវជ្រាវអប់រំ

ការស្រាវជ្រាវអប់រំគឺជាដំណើរការដែលប្រើវិធីសាស្រ្តវិទ្យាសាស្រ្តដើម្បីសិក្សាស្វែងយល់ និងដោះស្រាយ បញ្ហាដែលទាក់ទងនឹងការអប់រំ។ វាជួយបង្កើតចំណេះដឹងថ្មី ឬបញ្ជាក់អំពីអ្វីដែលមានស្រាប់ ដើម្បីធ្វើឲ្យប្រព័ន្ធអប់រំ ការបង្រៀន និងការរៀន មានប្រសិទ្ធភាពកាន់តែច្រើន។

## IV.ចំណាត់ថ្នាក់នៃការស្រាវជ្រាវអប់រំ

ចំណាត់ថ្នាក់នៃការស្រាវជ្រាវ (Classification of Research) ចែកចេញជាច្រើនផ្នែក ដោយផ្អែកលើគោលបំណង និងវិធីសាស្រ្ត។ ខាងក្រោមជាចំណាត់ថ្នាក់សំខាន់ៗ៖

### ១. ចំណាត់ថ្នាក់តាមគោលបំណង

- ការស្រាវជ្រាវមូលដ្ឋាន (Basic/Pure Research)

សិក្សាដើម្បីបង្កើនចំណេះដឹងទូទៅ

  - ✓ មិនចង់បានអនុវត្តភ្លាមៗ
  - ✓ ឧទាហរណ៍៖ ស្រាវជ្រាវអំពីទ្រឹស្តីការរៀន
- ការស្រាវជ្រាវអនុវត្ត (Applied Research)
  - ✓ ដើម្បីដោះស្រាយបញ្ហាជាក់ស្តែង
  - ✓ ឧទាហរណ៍៖ ស្រាវជ្រាវអំពីវិធីបង្រៀនថ្មីដើម្បីលើកកម្ពស់ពិន្ទុសិស្ស

### ២. ចំណាត់ថ្នាក់តាមវិធីសាស្រ្ត

- ស្រាវជ្រាវគុណភាព (Qualitative Research)
  - ✓ ផ្តោតលើការយល់ដឹងស៊ីជំរៅ
  - ✓ ប្រើសម្ភាសន៍ សង្កេត អត្ថបទ
- ស្រាវជ្រាវបរិមាណ (Quantitative Research)
  - ✓ ប្រើទិន្នន័យចំនួន និងស្ថិតិ
  - ✓ ឧទាហរណ៍៖ ការសិក្សាប្រៀបធៀប
- ស្រាវជ្រាវចម្រុះ (Mixed Methods)
  - ✓ ផ្សំគ្នារវាងគុណភាព និងបរិមាណ

### ៣. ចំណាត់ថ្នាក់តាមរចនាស្រាវជ្រាវ

- ការស្រាវជ្រាវពិពណ៌នា (Descriptive Research)
  - ពិពណ៌នាអំពីបាតុភូត ឬស្ថានភាព
- ការស្រាវជ្រាវទំនាក់ទំនង (Correlational Research)
  - សិក្សាថាតើអថេរច្រើនមានទំនាក់ទំនងគ្នាដែរ ឬទេ?
- ការស្រាវជ្រាវសាកល្បង (Experimental Research)
  - មានការត្រួតពិនិត្យអថេរ និងប្រើក្រុមធម្មតា និងក្រុមពិសោធន៍
- ការស្រាវជ្រាវប្រតិបត្តិ (Action Research)
  - ផ្តោតលើការកែលម្អអនុវត្តន៍ (ឧទាហរណ៍៖ ការបង្រៀន)

## V.ជំហាននៃការស្រាវជ្រាវអប់រំ

ជំហាននៃការស្រាវជ្រាវអប់រំមាន៖

1. កំណត់បញ្ហាស្រាវជ្រាវ (Identifying the research problem)៖ កំណត់បញ្ហា ឬសំណួរស្រាវជ្រាវដែលចង់ដោះស្រាយ។
2. រំលឹកទ្រឹស្តី (Review of related literature)៖ សិក្សាអត្ថបទ ឯកសារបច្ចេកទេស និងការស្រាវជ្រាវមុនៗ ដើម្បីស្វែងយល់ពីចំណេះដឹងដែលមានស្រាប់។
3. កំណត់គោលបំណង និងសំណួរស្រាវជ្រាវ (Formulating objectives and research questions /hypotheses)៖ កំណត់អ្វីដែលស្រាវជ្រាវចង់សម្រេច និងសំណួរដែលត្រូវឆ្លើយ។
4. បង្កើតផែនការស្រាវជ្រាវ (Choosing research design and methodology)៖ កំណត់ប្រភេទស្រាវជ្រាវ (គុណភាព/បរិមាណ/លាយបញ្ចូល) និងវិធីសាស្ត្រដែលនឹងប្រើ។
5. អភិវឌ្ឍឧបករណ៍ប្រមូលទិន្នន័យ (Developing research instruments)៖ ឧទាហរណ៍៖ សំណួរសម្ភាសន៍ សង្កេត តេស្ត។
6. ប្រមូលទិន្នន័យ (Collecting data)៖ ប្រើឧបករណ៍ ដើម្បីប្រមូលទិន្នន័យតាមផែនការ។
7. វិភាគទិន្នន័យ (Analyzing data)៖ ប្រើស្ថិតិ (quantitative) ឬកូដ/ធ្វើ thematic analysis (qualitative)។
8. បកស្រាយលទ្ធផល (Interpreting results)៖ បកស្រាយថាតើលទ្ធផលមានន័យអ្វី ទាក់ទងទៅនឹងសំណួរស្រាវជ្រាវ។
9. សរសេររបាយការណ៍ និងចែករំលែក (Writing and reporting research)៖ សរសេរព័ត៌មានជាស្ថាពរ (thesis, article, report) និងផ្សព្វផ្សាយ។

## VI.សារៈសំខាន់នៃការស្រាវជ្រាវអប់រំ

1) **កែលម្អគុណភាពបង្រៀន និងរៀន**៖ ការស្រាវជ្រាវអប់រំជួយគ្រូបង្រៀនរកឃើញវិធីសាស្ត្រថ្មីៗ ដើម្បីធ្វើឲ្យការបង្រៀនមានប្រសិទ្ធភាព និងសិស្សមានចំណេះដឹងច្បាស់លាស់ជាងមុន។
2) **ជួយដោះស្រាយបញ្ហា**៖ ជួយស្វែងយល់ និងដោះស្រាយបញ្ហាដែលកើតមានក្នុងថ្នាក់រៀន និងសាលារៀន ដូចជា ការសិក្សាទាប ឬការខ្វះចំណូលចិត្តក្នុងការរៀន។
3) **ផ្តល់មូលដ្ឋានសម្រាប់ធ្វើគោលនយោបាយអប់រំ**៖ លទ្ធផលស្រាវជ្រាវអាចប្រើសម្រាប់ការកំណត់យុទ្ធសាស្ត្រ ឬគោលនយោបាយរដ្ឋាភិបាលក្នុងវិស័យអប់រំ។
4) **លើកកម្ពស់ការអនុវត្តជំនាញគរុកោសល្យ**៖ ជួយគ្រូបង្រៀនអភិវឌ្ឍសមត្ថភាពផ្នែកវិជ្ជាជីវៈ ដោយយល់ពីអ្វីដែលមានប្រសិទ្ធភាពក្នុងការបង្រៀន។
5) **បង្កើនចំណេះដឹងវិទ្យាសាស្ត្រ**៖ ជួយបន្ថែមចំណេះដឹងស្តីពីទ្រឹស្តីអប់រំ និងផ្តល់គំរូឲ្យអ្នកស្រាវជ្រាវនាពេលក្រោយ។

## ឯកសារយោង


1) Creswell, J. W., & Creswell, J. D. (2018). *Research design: Qualitative, quantitative, and mixed methods approaches* (5th ed.). SAGE Publications.

2) Kothari, C. R. (2004). *Research methodology: Methods and techniques* (2nd ed.). New Age International Publishers.
3) Cohen, L., Manion, L., & Morrison, K. (2018). *Research methods in education* (8th ed.). Routledge.
4) Kumar, R. (2019). *Research methodology: A step-by-step guide for beginners* (5th ed.). SAGE Publications.
5) Creswell, J. W. (2012). *Educational research: Planning, conducting, and evaluating quantitative and qualitative research* (4th ed.). Pearson.
6) Gay, L. R., Mills, G. E., & Airasian, P. (2011). *Educational research: Competencies for analysis and applications* (10th ed.). Pearson.
7) Gay, L. R., Mills, G. E., & Airasian, P. W. (2012). *Educational research: Competencies for analysis and applications* (10th ed.). Pearson.
8) Fraenkel, J. R., Wallen, N. E., & Hyun, H. H. (2019). *How to design and evaluate research in education* (10th ed.). McGraw-Hill Education.